# ឡើងអ្នកតានៅសំបូរព្រៃគុក

សំបូរព្រៃគុក គឺជាក្រុមប្រាសាទស្ថិតនៅទិសឦសាននៃទីរួមខេត្តកំពង់ធំ ដែលជារមណីយដ្ឋានប្រវត្តិសាស្ត្ររីកចម្រើនខ្លាំងក្នុងអំឡុងសតវត្សរ៍ទី៧នៃគ្រិស្តសករាជនិងមានឈ្មោះដើមថា "ឦសានបុរ"។ ពាក់ព័ន្ធនឹងក្រុមប្រាសាទសំបូរព្រៃគុក គេសង្កេតឃើញតែងប្រារព្ធពិធីឡើងអ្នកតាពីរដងក្នុងមួយឆ្នាំ ពោលគឺនៅវេលាខាងដើមឆ្នាំម្តងនិងក្នុងវេលាខាងចុងឆ្នាំម្តង។[1] អ្នកស្រាវជ្រាវយល់ថា ពិធីទាំងពីរបានបង្ហាញឱ្យឃើញពីអត្ថន័យសំខាន់ពាក់ព័ន្ធនឹងការងារកសិកម្មធ្វើស្រែចម្ការរបស់អ្នកស្រុក ជាប់នឹងជំនឿលើអ្នកតាថែរក្សាទឹកដីរបស់គេ។ ក្នុងអត្ថបទខាងក្រោម ខ្ញុំសូមរៀបរាប់យ៉ាងសង្ខេបអំពីពិធីឡើងអ្នកតានៅភូមិសំបូរ ហើយមានទំនាក់ទំនងនឹងប្រាសាទសំបូរព្រៃគុក ដែលគេតែងប្រារព្ធបន្ទាប់ពីចាប់ការងារច្រូតកាត់ប្រមូលផលស្រូវរួច។

ជាការពិត ទំនៀមឡើងអ្នកតានៅភូមិសំបូរ ជាប្រពៃណីមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងមនុស្ស បរិស្ថាន និងបុរាណដ្ឋាន ពោលគឺជំនឿរបស់អ្នកស្រុក និងក្រុមប្រាសាទសំបូរព្រៃគុក ដ្បិតក្នុងដំណើរនៃពិធីឡើងអ្នកតា គេត្រូវចេញទៅចាប់ត្រី រកអណ្តើក និងបាញ់ស្វា ដែលស្ថិតនៅក្នុងព្រៃប្រាសាទ និងបរិស្ថានជុំវិញសម្រាប់រៀបចំពិធី និងធ្វើជាសំណែនថ្វាយអ្នកតា។ ទន្ទឹមនឹងនោះ អ្នកភូមិភាគច្រើនតែងមានទម្លាប់ធ្វើនំនាលដែលជានំលេខមុខមាត់ជាងគេក្នុងកិច្ចឡើងអ្នកតា។[2]

ជាទូទៅពិធីឡើងអ្នកតារបស់អ្នកភូមិសំបូរ តែងប្រារព្ធនៅរវាងដើមខ្នើតខែមាឃ ហើយគេតែងមូលមាត់កំណត់យកថ្ងៃណាមួយទៅតាមការកំណត់របស់ព្រឹទ្ធាចារ្យក្នុងភូមិដែលគេហៅថា "ចៅមឿង"។ ដោយឡែកចំពោះដំណើរនៃការប្រារព្ធពិធីឡើងអ្នកតានេះ គេស្ទើរតែអាចនិយាយខ្លីថាអ្នកស្រុកចាប់ផ្តើមខ្វល់ខ្វាយគិតគូរតាំងពីរវាងពីរទៅបីថ្ងៃមុនពិធី ពោលគឺក្រុមខ្លះចេញទៅចាប់ត្រី រាវអណ្តើក និងបាញ់ស្វា ដើម្បីផ្គត់ផ្គង់ក្នុង

[1] សូមបញ្ជាក់ថា "ឆ្នាំ" ដែលកំពុងនិយាយនេះគឺជាឆ្នាំនៃវដ្តស្រូវ។ សូមអាន៖ សាន់ ស៊ីថុន ២០០៧-២០០៨: ២២-២៤, អាន រស្មី ២០១១, និង ម៉ង់ រ៉ាលី "កិច្ចច្រត់ព្រះនង្គ័លនៅតំបន់ប្រាសាទសំបូរព្រៃគុក" ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/27630 (ចូលអាន ១ មករា ២០២៤)

[2] អាំង ជូលាន ២០០៨-២០០៩: ២-៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ពិធី និងធ្វើជាសំណែនអ្នកតា។ ក្រុមខ្វះទៀត (អ្នកស្រុកហៅក្រុមរៃរបៃ?) ត្រូវចេញដើររៃអង្គាសតាមផ្ទះនូវវត្ថុសំខាន់ៗមួយចំនួនសម្រាប់ធ្វើជាតង្វាយក្នុងពិធីដូចជា នំនាល អន្សមផ្អាវ និងស្រា។ ប៉ុន្តែក្នុងពេលនោះ អ្នកភូមិខ្លះក៏ចូលរួមបន្ថែមទៀតដូចជាប្រាក់ ទៀន ធូប និងភេសជ្ជៈជាដើម បើទោះបីពិធីនេះពុំឃើញមានរៀបចំកិច្ចពាក់ព័ន្ធនឹងព្រះសង្ឃដូចទំនៀមខ្លះទៀតក៏ដោយ (រូបលេខ១-២)។





រូបលេខ១-២ អ្នកភូមិយកនំនាល និងស្រាមកចូលរួមជាមួយក្រុមអ្នកដើររៃអង្គាល

ចំពោះលំដាប់លំដោយនៃពិធីឡើងអ្នកតា គឺគេត្រូវត្រៀមរៀបចំតង្វាយ និងម្ហូបសម្រាប់ពិធីនេះច្រើនថ្ងៃមុន ដូចរៀបរាប់ខ្លះៗមកខាងលើ។ លុះដល់ថ្ងៃកំណត់ឡើងអ្នកតា កិច្ចសំខាន់ៗចាប់ផ្តើមតាំងពីវេលាម៉ោងប្រហែលជាង១០ព្រឹក ដោយមានចាស់ទុំនាំគ្នាឡើងលើផ្ទះរូបស្នង ធ្វើកិច្ចរួចហើយដង្ហែរូបស្នងនោះ និងវណ្ណាប់តម្រង់ទៅខ្ទមអ្នកតាទ្វារ ដែលស្ថិតនៅក្នុងភូមិ (រូបលេខ៣) និងឃ្វាតបរិវេណប្រាសាទប្រហែលជាង២គីឡូម៉ែត្រ។ នៅទីនោះគេប្រគំភ្លេងប្រហែល៣បទ រួចមានស្ត្រីដែលកាន់គ្រូអារក្សរាំឡូកកញ្ឆេងសប្បាយ លាបម្សៅ ក្រែម បាញ់ទឹកអប់... នៅមុខរូបខ្ទមអ្នកតា ហើយជួនកាលអ្នកស្រុកចូលទៅឱ្យរូបស្នងស្តោះផ្លុំព្យាបាលជំងឺផងក៏មាន។ បន្ទាប់មកទើបគេធ្វើកិច្ចបញ្ជូន ដែលមានសំណែន និងវណ្ណាប់ផ្សេងៗបញ្ជូនទៅចោលក្នុងស្រែឆ្ងាយពីក្រៅភូមិ។ វណ្ណាប់សំខាន់ៗដែលគេសង្កេតឃើញមានដូចជា ជម ស្លាធម៌ បាយសី ពៃ មាន់ត្លង១គូ ស្លាធ្លាង ឃ្នងខ្មោះ រូបសេះ រូបដំរី ជើងត្រុំ សាលា រទេះគោ និងរទេះក្របី ដែលធ្វើពីដើមចេកជាដើម (រូបលេខ៤-៥)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៣ អ្នកភូមិដង្ហែរូបស្នងចេញពីផ្ទះទៅកាន់ខ្ទមអ្នកតាទ្វារ



រូបលេខ១៤ កិច្ចបញ្ចូលបញ្ឆាន់មុខខ្ទមអ្នកតាទ្វារ



រូបលេខ១៥ កិច្ចបញ្ជូនក្នុងស្រែខាងក្រៅភូមិ

ផុតពីកិច្ចបញ្ជូន គេដង្ហែរូបស្នងតាមវាលស្រែបន្តទៅកាន់ខ្ទមអ្នកតាចាស់ស្រុក ឬអ្នកខ្លះហៅថាអ្នកតាព្រៃធំ ដែលស្ថិតនៅក្នុងបរិវេណក្រុមប្រាសាទសំបូរព្រៃគុក។ នៅតាមផ្លូវ រូបស្នងនោះកាច់មែកឈើដោកន្ទេងមួយកណ្តាលស្រែសម្រាប់ធ្វើ"កិច្ចបំពេញឃ្លាំង"។ ទៅដល់ខ្ទមអ្នកតាចាស់ស្រុក ចាស់ទុំពីរបីនាក់ចាប់ផ្តើមសែនបូជាតង្វាយផ្សេងៗ ពិសេសគឺធាមីស្ងួសាច់អណ្តើក ដែលជាសំណែនសំខាន់។ រីឯរូបស្នងក៏ចូលទៅពិនិត្យសំណែនទាំងឡាយនោះ រួចក៏ទៅអង្គុយចាំទទួលតង្វាយពីអ្នកស្រុក ដែលមកសុំស្តោះផ្លុំព្យាបាលជំងឺ ដោយមានភ្លេងប្រគំកំដរ។ ទន្ទឹមគ្នានេះ អ្នកកាន់រូបអារក្សជាច្រើនឡើងរាំនៅមុខរូបស្នង និងមុខខ្ទមអ្នកតាដូចនៅមុខខ្ទមអ្នកតាទ្វារដែរ (រូបលេខ៦-៧)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




*រូបលេខ២៦-២៧ ទិដ្ឋភាពកិច្ចផ្សេងៗនៅខ្ទមអ្នកតាព្រៃធំក្នុងបរិវេញប្រាសាទសំបូរព្រៃគុក*

ពិធីនៅខ្ទមអ្នកតាចាស់ស្រុក បញ្ចប់ត្រឹមកិច្ចច្រូចស្រាក្នុងបំពង់ឫស្សីដាក់បញ្ឈរនៅលើថ្មប្រាសាទមានរាងដូចកាំជណ្ដើរក្បែរខ្ទមអ្នកតាចាស់ស្រុក ដែលកិច្ចត្រង់នេះហៅថា "កិច្ចបំពេញឃ្លាំង" (រូបលេខ២៨)។ កិច្ចបំពេញឃ្លាំងនេះ គេពន្យល់ថាធ្វើនៅក្នុងន័យឱ្យភោគផលស្រូវខាងមុខទៀត ទទួលបានច្រើនបរិបូណ៌។ ក្រោយពេលចប់ភ្វាម រូបស្នងដើរយ៉ាងលឿនសំដៅទៅទីស្រែដែលបានដៅទុក ដើម្បីធ្វើកិច្ចបំពេញឃ្លាំងម្ដងទៀត។ នៅទីនេះរូបស្នងនៅឈរទ្រឹងស្ងៀម តែមានមនុស្សចាស់ពីរបីនាក់ឈរនៅក្បែរ ដើរតួឆ្លងឆ្លើយគ្នា ហើយខ្វះនិយាយថាក្រុមខ្លួនមកពីដែនឆ្ងាយនៃក្រុងពារាណសីស្រីគ្រប់លក្ខណ៍នាំយកភោគផលមកឱ្យភូមិ។ ក្រោយមកគេបានចាក់ស្រាមួយភាគទៅក្នុងរណ្ដៅកណ្ដាលស្រែនោះ ហើយស្រែកហ៊ោសប្បាយទ្រហឹងអឺងកង (រូបលេខ២៩)។ រីឯរូបស្នងក៏បន្តដំណើរសំដៅមករោងពិធីនៅក្នុងភូមិវិញ ហើយគេបន្តលេងភ្លេងថ្វាយដល់រូបចាស់ស្រុក និងរូបផ្សេងៗទៀតដែលជាន់គ្រូអារក្ស ឱ្យចូលរាំសប្បាយ ហើយក៏មានមនុស្សចូលមកឱ្យចាស់ស្រុកស្ដោះបន្តបន្ទាប់ រហូតចប់ប្រហែលម៉ោង៤រសៀល។




*រូបលេខ២៨ កិច្ចបំពេញឃ្លាំងក្បែរខ្ទមអ្នកតាព្រៃធំ*

*រូបលេខ២៩ កិច្ចបំពេញឃ្លាំងនៅក្នុងវាលស្រែ*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ជារួមមក គេសង្កេតឃើញថាពិធីឡើងអ្នកតានៅសំបូរព្រៃគុកនេះ ហាក់បង្ហាញឱ្យឃើញពីជំនឿមួយរបស់អ្នកស្រុកចំពោះអ្នកតាដែលគេគោរពបូជាក្នុងភូមិនិងក្នុងបរិវេណប្រាសាទៗ កិច្ចសំខាន់ៗក្នុងពិធីនេះក៏ស្តែងឱ្យឃើញពីសារៈសំខាន់និងទំនាក់ទំនងជំនឿរវាងស្រែនិងអ្នកតា។ មិនតែប៉ុណ្ណោះ ក្រៅពីបង្ហាញឱ្យឃើញពីទិដ្ឋភាពពិធីឡើងអ្នកតាដ៏គគ្រឹកគគ្រេងមួយ ពិធីឡើងអ្នកតានៅសំបូរព្រៃគុកក៏នាំឱ្យគេមើលឃើញពីទំនៀមអ្នកស្រុក ដែលគោរពបូជាបុរាណដ្ឋានជាមត៌កដូនតា ឃើញពីម្ហូបអាហារប្រពៃណី និងយល់ពីតម្លៃនៃទំនាក់ទំនងវប្បធម៌ដ៏រស់រវើករវាងមនុស្ស ធម្មជាតិ និងបុរាណដ្ឋានផងដែរ។ សូមរំលឹកថាកាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៨ ក្រុមប្រាសាទសំបូរព្រៃគុកបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ៕

## ឯកសារយោង


ម៉ង់ វ៉ាលី

២០២៣, "កិច្ចប្រត់ព្រះនង្គ័លនៅតំបន់ប្រាសាទសំបូរព្រៃគុក" ផ្សាយលើគំណ https://ams.com.kh/khmercivilization/detail/27630 (ចូលអាន ១ មករា ២០២៤)

សាន់ ស៊ីថុន

២០០៧-២០០៨, "ប្រត់ព្រះនង្គ័ល", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៣, ទំ.២២-២៤, Friends of Khmer Culture, ភ្នំពេញ

អាន រស្មី

២០១១, *លៀងអារក្សនៅភូមិសំបូរ*, សារណាបញ្ចប់បរិញ្ញាបត្រមហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

អាំង ជូលាន

២០០៨-២០០៩ "ទំនាល", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៤, ទំ.២-៤, Friends of Khmer Culture, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត